# មេរៀនទី ១៥១៖ ព្រះការពារដានីយ៉ែលនៅក្នុងរូងសិង្ហ

## ដានីយ៉ែល ៦៖១-២៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/M6JmWc9_-Qk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/0jGXFzZcSTU

**គោលបំណង៖ យើងត្រូវតែស្មោះត្រង់ចំពោះព្រះ។**

**ខគម្ពីរចងចាំ៖ ដានីយ៉ែល ៦៖២២** *“ព្រះនៃទូលបង្គំទ្រង់បានចាត់ទេវតារបស់ទ្រង់ ឲ្យមកបិទមាត់សិង្ហទាំងអស់ វាមិនបានប្រទូស្តដល់ទូលបង្គំទេ ពីព្រោះនៅចំពោះព្រះ នោះមិនឃើញជាទូលបង្គំមានទោសអ្វីឡើយ ហើយបពិត្រព្រះករុណា នៅចំពោះទ្រង់ ទូលបង្គំក៏មិនបានធ្វើខុសអ្វីដែរ។”*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវល្អក្រៃលែង https://youtu.be/uFsMi06lhvE

២. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

៣. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ដានីយ៉ែល»



១. កុមារត្រូវធ្វើកាយការខុសៗគ្នាដើម្បីលេងល្បែងនេះ។

ក. ដានីយ៉ែល ៖កុមារត្រូវលើកដៃសំពះ ធ្វើជាអធិស្ឋាន

ខ. ពួកមន្ត្រី៖ ត្រូវចង្អុលក្បាលរបស់ពួកគេ

គ. តោ៖ កុមារត្រូវលើកដៃទាំងពីររបស់ពួកគេហើយធ្វើដូចជាតោគ្រហឹម ហើយដាក់ដៃនៅជិត ត្រចៀក របស់ពួកគេ។ ឲ្យកុមារហាមាត់ ដើម្បីបង្ហាញធ្មេញរបស់ ពួកគេ។

២. ចែកកុមារជាពីរក្រុមហើយឲ្យពួកគេឈរបែរខ្នងដាក់គ្នា។ ក្រុមនីមួយៗត្រូវធ្វើការពិភាក្សាថា ពួកគេត្រូវធ្វើកាយវិការមួយណា (ដានីយ៉ែល, តោ, ពួកមន្ត្រី)។

៣. គ្រូត្រូវប្រាប់កុមារថា(ដានីយ៉ែលឈ្នះតោ), (តោឈ្នះពួកមន្ត្រី),(ពួកមន្ត្រីឈ្នះដានីយ៉ែល)

៤.នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទាំងពីរក្រុមត្រូវបែរមុខមករកគ្នាហើយបង្ហាញពីកាយវិការរបស់ពួកគេ។ ប្រសិនបើក្រុមទាំងពីរធ្វើកាយវិការដូចគ្នា សូមឲ្យពួកគេលេងម្តងទៀត។

៥. ប្រសិនបើក្រុមណាឈ្នះបីដងនោះក្រុមគេនឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា នៅពេលដែលយើងចេះបន្ទាបខ្លួន និងស្មោះត្រង់ចំពោះព្រះ នោះព្រះនឹងការពារយើងពីរឿងអាក្រក់ទាំងអស់។

### ៤. ការណែនាំមេរៀន

តើអ្នកដឹងទេថាអ្វីទៅជាភាពស្មោះត្រង់? ភាពស្មោះត្រង់មានន័យថាការនៅជាប់ជាមួយនឹងអ្នកណាម្នាក់មិនថាមានបញ្ហាអ្វីក៏ដោយ។ តើអ្នកចង់មានភាពស្មោះត្រង់ចំពោះអ្នកណា? ចំពោះឪពុកម្តាយ? បងប្អូនបង្កើត? មិត្តភក្តិ? មនុស្សទាំងអស់នៅក្នុងពិភពលោក ត្រូវតែមានភាពស្មោះត្រង់ទៅចំពោះ ព្រះជាម្ចាស់។ យើងត្រូវតែនៅជាប់ជាមួយនឹងព្រះជាម្ចាស់មិនថានៅក្នុងស្ថានភាពបែបណានោះទេ។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ដែលមានឈ្មោះថាដានីយ៉ែល គាត់នៅតែស្មោះត្រង់ជាមួយនឹង ព្រះជាម្ចាស់មិនថាគាត់ស្ថិតនៅក្នុងស្ថានភាពបែបណាក៏ដោយ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលដានីយ៉ែលនៅក្មេង គាត់ត្រូវគេចាប់យកពីអ៊ីស្រាអែលទៅធ្វើជាឈ្លើយនៅបាប៊ីឡូន។ នៅពេលនោះ បាប៊ីឡូនត្រូវបានគ្រប់គ្រងដោយសាសន៍មេឌី និង ពើស៊ី ដូច្នេះហើយទើបមានស្តេចថ្មីមួយអង្គបាន ឡើងសោយរាជ្យដែលមានព្រះនាមថាដារីយុស។ ស្តេចអង្គនេះទ្រង់ស្រឡាញ់ចូលចិត្តដានីយ៉ែល ហើយបានលើកគាត់ឱ្យធ្វើជាអធិបតីម្នាក់ក្នុងចំណោម ៣ នាក់ដើម្បីត្រួតត្រាលើនគរនេះ។ តាមពិតទៅ ដានីយ៉ែលគឺជាមនុស្សល្អនិងឆ្លាតម្នាក់ដែលស្តេចដារីយុសចង់ឱ្យគាត់ធ្វើជាអ្នកត្រួតលើនគរទាំងមូលតែម្តង។ ប៉ុន្តែពួកចៅហ្វាយអធិបតីផ្សេងទៀតដែលគេមិនចូលចិត្តគាត់មានគម្រោងចង់កម្ចាត់ដានីយ៉ែលចោលវិញ។ ប៉ុន្តែពួកគេមិនអាចចាប់កំហុសរបស់ដានីយ៉ែលបានឡើយដោយព្រោះគាត់ជាមនុស្សល្អ។

ក្រោយមកនៅថ្ងៃមួយ ពួកអធិបតីទាំងនោះបានទៅគាល់ស្តេច ដោយទូលសូមឱ្យទ្រង់បង្កើតនូវច្បាប់ដ៏តឹងរ៉ឹងមួយដោយមិនអនុញ្ញាតឱ្យអ្នកណាទូលសូមអ្វីពីព្រះជាម្ចាស់បាន លើកលែងតែស្តេចប៉ុនណោះ។ ពួកគេក៏បាននិយាយផងដែរថា អ្នកណាដែលហ៊ានអធិស្ឋានទៅព្រះណាក៏ដោយ នឹងត្រូវបោះចូលទៅក្នុងរូងសឹង្ហ។ នេះគឺដោយព្រោះពួកគេដឹងថាដានីយ៉ែលស្រឡាញ់ព្រះជាម្ចាស់ ហើយគាត់នឹងមិនឈប់ អធិស្ឋានទៅចំពោះព្រះឡើយ។ ស្តេចដារីយុសបានចុះហត្ថលេខានៅលើច្បាប់នោះ និងប្រកាសមិន អនុញ្ញ ត ឱ្យអ្នកណាម្នាក់អធិស្ឋានទូលសូមនូវអ្វីពីព្រះ ឬពីមនុស្សបានឡើយ លើកលែងតែស្តេច១ ប៉ុនណោះ។

នៅពេលដែលដានីយ៉ែលបានដឹងដំណឹងពីលិខិតដែលស្តេចបានដាក់ចេញជាច្បាប់នោះ គាត់បានត្រឡប់ទៅផ្ទះវិញ ហើយអធិស្ឋានទៅព្រះជាម្ចាស់ព្រមទាំងបើកបង្អួចផងដែរ គាត់អធិស្ឋាន ៣ ដងក្នុងមួយថ្ងៃ តាមទម្លាប់ដែលគាត់ធ្លាប់ធ្វើ! គាត់មិនភ័យខ្លាចក្នុងការអធិស្ឋានទៅកាន់ព្រះ ទោះបីជាគាត់ត្រូវគេបោះចូលទៅក្នុងរូងសិង្ហក៏ដោយ!

បន្ទាប់ពីឃើញបែបនេះហើយ ពួកមន្រ្តីទាំងនោះបានចូលទៅគាល់ស្តេច ហើយទូលទ្រង់ថាដានីយ៉ែលបានអធិស្ឋានទៅព្រះ ហើយពួកគេបានស្នើសុំឱ្យស្តេចដាក់ពិន័យចំពោះដានីយ៉ែល។ ស្តេចដារីយុស មិនសប្បាយព្រះទ័យជាខ្លាំងដែលបានឮបែបនេះ ពីព្រោះទ្រង់សព្វព្រះហឫទ័យចំពោះដានីយ៉ែល ប៉ុន្តែព្រះអង្គក៏មិនអាចផ្លាស់ប្តូរនូវច្បាប់ដែលទ្រង់បានចេញហើយនោះដែរ ដូច្នេះហើយទើបទ្រង់បានបញ្ជាឱ្យគេយកដានីយ៉ែលទៅបោះទៅក្នុងរូងសិង្ហ។

នៅថ្ងៃបន្ទាប់ ស្តេចបានត្រលប់ទៅកាន់រូងសិង្ហដើម្បីមើលថាតើដានីយ៉ែលយ៉ាងម៉េចទៅហើយ ដោយទ្រង់គិតថាគាត់ត្រូវបានសិង្ហស៊ីបាត់ទៅហើយ។ ប៉ុន្តែសិង្ហទាំងនោះមិនបានស៊ីដានីយ៉ែលនោះទេ ពីព្រោះព្រះបានចាត់ទេវតារបស់ទ្រង់ ឲ្យមកបិទមាត់សិង្ហទាំងអស់នោះ។ ស្តេចទ្រង់មានព្រះទ័យរីករាយក្រៃលែងដែលព្រះបានការពារជីវិតដានីយ៉ែល!

យើងត្រូវតែស្មោះត្រង់ចំពោះព្រះ បើទោះបីជាមានការពិបាកក្នុងការបង្ហាញនូវភាពស្មោះត្រង់ក៏ដោយ។ ព្រះតែងតែគង់ជាមួយយើង ជាពិសេសនៅពេលដែលមានការលំបាក។ ព្រះមិនបានរារាំងដានីយ៉ែលមិនឱ្យជួបនូវបញ្ហានោះទេ ប៉ុន្តែទ្រង់គង់ជាមួយនឹងដានីយ៉ែលនៅពេលដែលគាត់ កំពុងនៅក្នុងបញ្ហាតែម្តង។ ហេតុផលផ្សេងទៀតដែលយើងត្រូវតែស្មោះត្រង់ចំពោះព្រះគឺព្រះអង្គទ្រង់បរិសុទ្ធ។ បរិសុទ្ធគឺមានន័យថាគឺល្អឥតខ្ចោះ។ យើងរាល់គ្នាមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែព្រះរបស់យើងទ្រង់បរិសុទ្ធ។ ហើយអ្វីដែលអស្ចារ្យអំពីព្រះនោះគឺថា យើងមិនចាំបាច់ធ្វើអ្វីគ្រប់យ៉ាងឱ្យល្អឥតខ្ចោះ ដើម្បីឱ្យទ្រង់ ទទួលយើងនោះទេ។ ព្រះយេស៊ូវ មានជីវិតដ៏ល្អឥតខ្ចោះសម្រាប់យើងរាល់គ្នា! យើងគ្រាន់តែស្គាល់ និងស្រឡាញ់ទ្រង់ប៉ុនណោះ។ ហើយព្រះអង្គនឹងជួយយើងឱ្យបានជាបរិសុទ្ធដូចទ្រង់ដែរ។

មិនថាមានបញ្ហាអ្វីកើតឡើងនៅក្នុងជីវិតនោះទេ យើងត្រូវតែស្មោះត្រង់នៅចំពោះព្រះជាម្ចាស់ជានិច្ច ដែលមានន័យថាយើងត្រូវតែនៅជាប់ជាមួយទ្រង់។ ហើយយើងត្រូវតែជឿថា ព្រះជាម្ចាស់គឺតែងតែគង់ជាមួយយើងគ្រប់ពេលទាំងអស់។

## ៦. សំនួរពិភាក្សា

១. តើស្តេចនៃសាសន៍មេឌី និង ពើស៊ីមានព្រះនាមអ្វី? *(ស្តេចដារីយុស)*
២. តើស្តេចនោះចង់ធ្វើអ្វីចំពោះដានីយ៉ែល? *(គាត់ជាមន្ត្រីជំនិតម្នាក់ក្នុងចំណោម ៣ នាក់ដើម្បីគ្រប់គ្រងនគរ ប៉ុន្តែស្តេចចង់ឱ្យគាត់ក្លាយជាអ្នកត្រួតត្រាលើនគរទាំងមូលតែម្តង)*
៣. តើពួកមន្ត្រីផ្សេងទៀតធ្វើអ្វីដើម្បីបញ្ឈប់ដានីយ៉ែលពីការឡើងធ្វើជាអ្នកត្រួតត្រាលើនគរទាំងមូល? *(ពួកគេបានទូលស្តេចឱ្យចេញនូវលិខិតបម្រាមមួយដោយមិនឱ្យអ្នកណាអធិស្ឋានទូលសូមទៅព្រះ ឬមនុស្សណាបានទេ ក្នុងកំឡុងពេល ៣០ ថ្ងៃ លើកលែងតែស្តេចប៉ុណ្ណោះ បើមិនដូច្នេះទេ អ្នកនោះនឹងត្រូវបោះចូលទៅក្នុងរូងសិង្ហ)*
៤. បន្ទាប់ពីដឹងដំណឹងពីលិខិតបម្រាមរបស់ស្តេចហើយ តើដានីយ៉ែលធ្វើអ្វី? *(គាត់នៅអធិស្ឋានទៅចំពោះព្រះ ១ថ្ងៃបីដងដូចធម្មតា ព្រមទាំងបើកបង្អួចទៀតផង)*
៥. តើអ្នកណាដែលបានជួយដានីយ៉ែលពីក្នុងរូងសិង្ហ? *(ទេវតារបស់ព្រះបានបិទមាត់សិង្ហដែលស្រេកឃ្លានទាំងនោះ)*
៦. តើប្អូនអាចធ្វើអ្វីដើម្បីបង្ហាញនូវភាពស្មោះត្រង់របស់ប្អូនទៅចំពោះព្រះជាម្ចាស់? *(សូមឱ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «អាឡូ»




១. ឲ្យកុមារប៉ាវរកអ្នកចាញ់ចុងក្រោយម្នាក់ ហើយ ឲ្យគេធ្វើជា អ្នកចាំទី
២. កុមារត្រូវរត់ក្នុងបរិវេណថ្នាក់រៀន
៣. អ្នកអាចនិយាយពាក្យថា "អាឡូ" នៅពេលដែលអ្នកមិនចង់ឲ្យអ្នកចាំទីចាប់បាន។ អ្នកអាច បន្តរត់លេងបាន នៅពេលដែលមាននរណាម្នាក់មកប៉ះអ្នក ដែលមិនមែនជាអ្នកចាំទី។
៤. បើអ្នកចាំទី ប៉ះអ្នកបានមុនពេលដែលអ្នកនិយាយ ពាក្យថា "អាឡូ" នោះអ្នកនឹងក្លាយជាអ្នកចាំទីវិញ ម្តង។
៥. បន្ទាប់ពីលែងល្បែងនេះចប់ សូមពន្យល់កុមារថា យើងអាចស្រែកថា "អាឡូ" ដើម្បីកុំឲ្យអ្នកចាំទី ចាប់យើងបាន។ ហើយនៅក្នុងវិធីដូចគ្នានេះ នៅពេលដែលដានីយ៉ែលស្មោះត្រង់ចំពោះព្រះ ព្រះអាចទប់ស្កាត់




តោដែលកំពុងតែស្រេកឃ្លានមិនឲ្យសម្លាប់ដានីយ៉ែលបាន។ សូមចាំថា យើងត្រូវតែស្មោះត្រង់ចំពោះព្រះជានិច្ច។

## ៨. ខគម្ពីរចងចាំ

**ដានីយ៉ែល ៦៖២២** *"ព្រះនៃទូលបង្គំទ្រង់បានចាត់ទេវតារបស់ទ្រង់ ឲ្យមកបិទមាត់សិង្ហ ទាំង អស់ វាមិនបានប្រទូស្តដល់ទូលបង្គំទេ ពីព្រោះនៅចំពោះព្រះ នោះមិនឃើញជាទូលបង្គំមានទោស អ្វីឡើយ ហើយបពិត្រព្រះករុណា នៅចំពោះទ្រង់ ទូលបង្គំក៏មិនបានធ្វើខុសអ្វីដែរ។"*

## ៩. ហត្ថកម្ម "ព្រះការពារដានីយ៉ែលនៅក្នុងរូងសិង្ហ"



សំភារៈដែលត្រូវការ៖ សូមបោះពុម្ភក្រដាសហត្ថកម្ម, កូល័រផាត់ពណ៌ ការបិត និង កន្ត្រៃ



១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក
២. ឱ្យកុមារផាត់ពណ៌រូបសិង្ហនោះ
៣. បត់ផ្នែកមាត់របស់សត្វសិង្ហចូលគ្នាដើម្បីឱ្យឃើញមុខរបស់សត្វសិង្ហមានរាងមូល
៤. ឱ្យកុមារបើក/បិទមាត់របស់សត្វសិង្ហ ដើម្បីឱ្យពួកគេអាចមើលឃើញនូវខគម្ពីរចងចាំ នឹងអាចជួយគេឱ្យចងចាំនូវខគម្ពីរនោះ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)
ដានីយ៉ែលបានប្រឈមមុខនឹងការលំបាកដ៏ធំ តែគាត់នៅទ្រាំបានដោយសារតែគាត់មានទំនាក់ទំនងយ៉ាងខ្លាំងក្លាជាមួយនឹងព្រះ។ ដូចជាដានីយ៉ែល ដែលបានឆ្លើយតបទៅកាន់ស្តេច ហើយក៏ជាជនរងគ្រោះដោយសារតែការញោះញង់ យើងក៏អាចឆ្លើយតបទៅកាន់មនុស្សដទៃ និង តស៊ូជាមួយនឹងការលំបាកជារៀងរាល់ថ្ងៃ។ សូមអានព្រះគម្ពីរ ដានីយ៉ែល ៦៖១០-១១ សារឡើងវិញ នៅពេលដែលស្ថានភាពដានីយ៉ែលស្ថិតនៅក្នុងភាពអវិជ្ជមានក៏ដោយ ក៏គាត់នៅតែរក្សានូវដួងចិត្តដែលពេញដោយការអរព្រះគុណ និង អធិស្ឋានទៅចំពោះព្រះ។ នៅថ្ងៃនេះតើយើងចង់អរព្រះគុណព្រះពីរឿងអ្វីដែរ? តើអ្នកត្រូវការអ្វីពីព្រះជាម្ចាស់? សូមទូលប្រាប់ទ្រង់! ទូលសូមព្រះអង្គ និង ធ្វើវាដោយស្ងប់ចិត្តចុះ!

# ព្រះការពារដានីយ៉ែលនៅក្នុងរូងសិង្ហ



១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក

២. ឱ្យកុមារផាត់ពណ៌រូបសិង្ហនោះ

៣. បត់ផ្នែកមាត់របស់សត្វសិង្ហចូលគ្នាដើម្បីឱ្យឃើញមុខរបស់សត្វ
សិង្ហមានរាងមូល

៤. ឱ្យកុមារបើក/បិទមាត់របស់សត្វសិង្ហ ដើម្បីឱ្យពួក
គេអាចមើលឃើញនូវខគម្ពីរចងចាំ នឹងអាចជួយគេឱ្យចងចាំនូវខគម្ពីរនោះ។

